# មេរៀនទី១៥៖ កូនពៅវង្វេង

## លូកា ១៥៖១១-៣២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/xzABQsGhdDo

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/pbK75WGRatw

**គោលបំណង៖** ព្រះអង្គជាព្រះនៃសេចក្តីស្រឡាញ់ និងការអត់ទោស

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ១៤៥៖៨** *ព្រះយេហូវ៉ាទ្រង់ប្រកបដោយមេត្តាករុណានិងអាណិតអាសូរទ្រង់យឺតនឹងខ្ញាល់ ក៏មានសេចក្តីសប្បុរសដ៏ធំទូលាយ"។*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយេស៊ូវស្រលាញ់កុមារណាស់ https://youtu.be/8iUI62Zo_Co

២. ខ្ញុំដឹងខ្លួនហើយ https://youtu.be/cNotISrjHI0

៣. ចូរបន្ទាបខ្លួននៅចំពោះ ព្រះអង្គ https://youtu.be/7WO74xMesGU

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត

សំភារៈដែលត្រូវការ៖ ក្រដាសដែលមានពាក្យថា *"អំពើបាប" "សេចក្តីស្រឡាញ់"* និង *"ការអត់ទោស"* នៅលើនោះ ( សូមមើលទំព័រខាងក្រោម )

| |
|---|
| អំពើបាប |
| សេចក្តីស្រឡាញ់ |
| ការអត់ទោស |

១. សូមបត់ក្រដាសទាំងនោះ រួចចែកឲ្យទៅកុមារដែលមានទាំងពាក្យថា *"អំពើបាប" "សេចក្តីស្រឡាញ់"* និង *"ការអត់ទោស"*

២. ពេលដែលកុមារបានទទួលក្រដាសគ្រប់គ្នាហើយ សុំឲ្យពួកគេបើកក្រដាសនោះមើល។

៣. កុមារដែលកាន់ក្រដាសដែលមានពាក្យថា *"អំពើបាប"* ត្រូវស្វែងរក កុមារណាដែលកាន់ក្រដាស *"សេចក្តីស្រឡាញ់"* ឬ *"ការអត់ទោស" (ពួកគេក៏អាចស្វែងរកអ្នកដែលមានពាក្យថា "សេចក្តីស្រឡាញ់" និង "ការអត់ទោស" ទាំងពីរក៏បាន)*

៤.កុមារដែលកាន់ក្រដាសដែលមានពាក្យថា *"សេចក្តីស្រឡាញ់"* និង *"ការអត់ទោស"*ត្រូវស្វែងរក អ្នកណាដែលមានក្រដាសពាក្យថា *"អំពើបាប"*។

៥. ក្រុមណាដែលមានទាំង *"អំពើបាប"+"ការអត់ទោស"* ឬ *"អំពើបាប"+"សេចក្តីស្រឡាញ់"* ឬ *"អំពើបាប"+"សេចក្តីស្រឡាញ់"+ "ការអត់ទោស"*អាចអង្គុយចុះបាន។

៦. បើសិនកុមារៗណាដែលមានក្រដាសពាក្យថា *"អំពើបាប"* មិនអាចស្វែងរកអ្នកដែលមានពាក្យថា *"សេចក្តីស្រឡាញ់"* និង *"ការអត់ទោស"* បាន ពួកគេអាចចូលអង្គុយជាមួយក្រុម *"ក្តីស្រឡាញ់"* ឬ *"ការអត់ទោស"*មួយណាក៏បាន។

៧. សូមពន្យល់កុមារថាពេលដែលពួកគេធ្វើរឿងមិនល្អ នោះគេហៅថាជាអំពើបាប។ ហើយនៅពេល ដែល

យើងធ្វើបាប យើងនឹងចេញឆ្ងាយពីព្រះ។ មានផ្លូវតែមួយប៉ុណ្ណោះដែលអាចសំអាតយើងពីអំពើបាប គឺតាមរយៈ សេចក្តីស្រឡាញ់ និងការអត់ទោសរបស់ព្រះ។

៨. សូមឲ្យកុមារទាំងអស់និយាយថា **ព្រះស្រឡាញ់ខ្ញុំ ហើយទ្រង់អត់ទោសឲ្យខ្ញុំ**”។

## ៤. ការណែនាំមេរៀន

សំភារៈដែលត្រូវការ៖ ចានដែកជ័រធំមានទឹក ប្រអប់ជ័រ ដុំថ្ម



១. ចាក់ទឹកចូលក្នុងចានដែកជ័រធំនោះ ហើយដាក់ឲ្យប្រអប់ជ័រអណ្តែតលើទឹក

២. នៅពេលដែលយើងមានទំនាក់ទំនងល្អជាមួយព្រះ យើងប្រៀបដូចជាប្រអប់ជ័រដែលអណ្តែតនៅលើទឹកអ៊ីចឹង។

៣. តែពេលដែលយើងប្រព្រឹត្តអំពើបាប យើងចាប់ផ្តើមលិចចូលទៅក្នុងទឹក។

៤. តើយើងអាចធ្វើការអាក្រក់អ្វីខ្លះ? (ឧទាហរណ៍៖ កុហក ឈ្លោះគ្នា លួច ស្អប់គ្នា) ការអាក្រក់ ទាំងអស់នេះជាអ្វីដែលយើងហៅថាអំពើបាប។



៥. ដាក់ថ្មចូលទៅក្នុងប្រអប់ជ័រនោះ ហើយឲ្យកុមាររៀបរាប់ពីអំពើបាបមួយ ចំនួនរហូតដល់ ប្រអប់ជ័រលិចចូលទៅក្នុងទឹក។

៦. តែនៅពេលដែលយើងត្រឡប់ទៅរកព្រះវិញ ហើយទូលសូមការអត់ទោស ព្រះទ្រង់នឹងអត់ទោសឲ្យយើង

៧. សូមឲ្យកុមារនិយាយពាក្យ “សូមទោសព្រះអង្គ សូមអត់ទោសឲ្យកូនផង” បន្ទាប់មកយកដុំថ្មចេញពីប្រអប់ជ័រនៅគ្រប់ពេលដែលពួកគេនិយាយពាក្យនេះរហូតដល់ថ្មទាំងអស់ត្រូវបានយកចេញ ហើយប្រអប់ជ័រអណ្តែតនៅលើទឹកវិញ។

៨. សូមចងចាំថាព្រះស្រឡាញ់យើង ហើយអត់ទោសឲ្យយើងពេលដែលយើងត្រឡប់មករកទ្រង់វិញ។

៩. សរុបមកវិញ តើអំពើបាបគឺជាអ្វីប្អូនៗ? អំពើបាបគឺជាការ គិតខុស និយាយខុស ធ្វើខុសដែលព្រះទ្រង់មិនសព្វព្រះហឫទ័យ។ ឲ្យកុមារក្រោកឈរ ហើយធ្វើកាយវិកាយជាមួយគ្នា។

- គិតខុស៖ យកដៃមកចង្អុលក្បាលរបស់យើង ។
- និយាយខុស៖ យកដៃមកចង្អុលមាត់ ។
- ធ្វើខុស៖ យើងក្តាប់ដៃទាំងពីរហើយដំដៃលើគ្នាចុះឡើងៗ។
- ដែលព្រះទ្រង់មិនសព្វព្រះហឫទ័យ៖ យើងយកដៃទាំង២ធ្វើខ្វែងគ្នាចុះឡើង។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

មានឪពុកម្នាក់មានកូនប្រុស២នាក់។ ឪពុកមានលុយជាច្រើនឲ្យកូនប្រុសរបស់គាត់ដើម្បីទុកជាមរតកមុនពេលដែលគាត់ស្លាប់។ ប៉ុន្តែកូនប្រុសពៅមិនចង់រង់ចាំទេ គាត់ក៏បាននិយាយថា “លោកឪពុកសូមឲ្យលុយមកខ្ញុំឥឡូវនេះមក” ឪពុកកើតទុក្ខជាខ្លាំងដែលឃើញកូនពៅរបស់គាត់មិនចេះរង់ចាំ ពីព្រោះការនេះបង្ហាញ ថាកូនពៅមិនបានស្រឡាញ់ឪពុកទេ។ ប៉ុន្តែឪពុកនៅតែឲ្យលុយនោះទៅគាត់។

កូនពៅបានចំណាយលុយទាំងអស់ទៅលើការសប្បាយរបស់គាត់។ គាត់បានចំណាយលុយទៅលើការជប់លៀង និងម្ហូបអាហារ ហើយចាយវាយជាមួយនឹងមិត្តភក្តិរបស់គាត់។ គ្រប់យ៉ាងដែលកូនពៅគិតគឺការសប្បាយភ្លើតភ្លើន។ កូនពៅមិនបានគិតពីឪពុក ឬពីក្តីស្រឡាញ់របស់ឪពុកចំពោះគាត់នោះទេ។

មិនយូរប៉ុន្មានកូនពៅក៏បានចាយលុយអស់។ គាត់មិនមានលុយសម្រាប់ទិញអាហារ ឬសំរាប់ចំណាយទៅលើផ្ទះដែលគាត់រស់នៅបានទេ។ កូនពៅមានការសោកស្ដាយណាស់ ដែលគាត់បានខ្ជះខ្ជាយលុយដែលឪពុកឲ្យ។ គាត់ចង់ត្រឡប់ទៅផ្ទះវិញ ប៉ុន្តែគាត់ខ្លាចថាឪពុករបស់គាត់នឹងខឹងគាត់។ ដូច្នេះគាត់ក៏បានសំរេចចិត្តថានឹង សុំឪពុករបស់គាត់ឲ្យទទួលយកគាត់ធ្វើជាអ្នកបំរើ តែមិនមែនទទួលជាកូនទេ។

ប៉ុន្តែពេលដែលឪពុកឃើញគាត់ពីចំងាយ ឪពុកក៏រត់សំដៅទៅរកកូនពៅ។ ឪពុករងចាំកូនពៅត្រឡប់មកវិញរៀងរាល់ថ្ងៃ។ ឪពុកមិនបានខឹងនឹងកូនពៅទេ គាត់សប្បាយចិត្តណាស់ដែលឃើញកូនពៅត្រឡប់មករកគាត់វិញ! ឪពុកដឹងថាកូនពៅស្ដាយនូវកំហុស ហើយដោយសារតែគាត់ស្រឡាញ់កូន ឪពុកបានអត់ទោសឲ្យកូនពៅ។ ឪពុកបានឲ្យសំលៀកបំពាក់ថ្មីទៅកូនពៅ ហើយបានរៀបចំកម្មវិធីជប់លៀងយ៉ាងធំថែមទាំងអញ្ជើញមិត្តភក្តិរបស់គាត់ទាំងអស់មកចូលរួមទៀតផង។

នេះជាព្រះហឫទ័យដែលព្រះមានសំរាប់អ្នក និងខ្ញុំ។ នៅពេលដែលយើងធ្វើអ្វីខុស ហើយសុំការអត់ទោស ព្រះមិនចង់អោយយើងលាក់បាំង ហើយរត់គេចពីព្រះអង្គនោះទេ។ ព្រះអង្គចង់ឲ្យយើងត្រឡប់ទៅរកទ្រង់វិញ ហើយទូលសុំការអត់ទោសពីទ្រង់។ ពេលដែលយើងធ្វើបែបនេះ ព្រះនឹងអត់ទោសឲ្យយើង ព្រោះទ្រង់ស្រឡាញ់យើង។

**៦. សំនួរពិភាក្សា**

១. តើកូនប្រុសមួយណាដែលមិនចង់រងចាំ ហើយបានសុំឪពុកឲ្យចែកមរតកឲ្យ? *(កូនពៅ)*

២. តើការនេះបង្ហាញពីអ្វីនៅពេលដែលកូនពៅសុំឪពុកចែកមរតក? *(បានបង្ហាញថា កូនពៅ របស់គាត់មិនស្រឡាញ់ឪពុកខ្លួនទេ)*

៣. តើកូនពៅយកលុយទៅចំណាយលើអ្វីខ្លះ? *(ផឹកស៊ី លេងល្បែងស៊ីសង ចូលក្លឹប សប្បាយជាមួយមិត្តភក្តិ និងស្រាស្រី)*

៤.តើឪពុកមានប្រតិកម្មដូចម្ដេច នៅពេលដែលកូនប្រុសបានត្រឡប់មកផ្ទះវិញបន្ទាប់ពីបានចាយលុយអស់? *( ឪពុកទទួលកូនដោយអោបថើប យកស្បែកជើងថ្មី អាវថ្មី ចិញ្ចៀន ស្រឡាញ់កូន និងអត់ទោសឲ្យកូន ហើយបានរៀបចំកម្មវិធីជប់លៀងយ៉ាងធំសំរាប់កូន)*

៥.តើព្រះនឹងធ្វើអ្វីពេលដែលយើងត្រឡប់មករកព្រះវិញជាមួយនឹងចិត្តសោកស្ដាយបន្ទាប់ពីបានធ្វើការអាក្រក់? *(ព្រះនៅតែស្រឡាញ់ ហើយអត់ទោសឲ្យយើង)*

**៨. ខគម្ពីរចងចាំ**

**ទំនុកដំកើង ១៤៥៖៨** *“ព្រះយេហូវ៉ាទ្រង់ប្រកបដោយមេត្តាករុណានិងអាណិតអាសូរទ្រង់យឺត នឹងខ្ញាល់ ក៏មានសេចក្តីសប្បុរសដ៏ធំទូលាយ”*។

**៩. ហាត្ថកម្ម**

សូមជួយកុមារៗឲ្យសរសេរខគម្ពីរចងចាំបន្ទាប់ពីពួកគេបានផាត់ពណ៌រួច ( សូមមើលនៅទំព័រខាងក្រោម )

**១០. ចំរៀង**

( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូះ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

វាប្រហែលជាមិនមែនជារឿងចៃដន្យនោះទេ ដែលឪពុកមើលកូនប្រុសពីចម្ងាយស្គាល់បាន។ លើសពីនេះនោះគឺគាត់កំពុងរង់ចាំមើលជារៀងរាល់ថ្ងៃកូនប្រុសរបស់គាត់ឲ្យត្រឡប់មកវិញ។ សូមសាកស្រមៃពីរូបភាពដែលព្រះទ្រង់អន្ទះសារចង់ជួបអ្នក បើទោះបីជាពេលអ្នកមានអារម្មណ៍អៀនខ្មាសក៏ដោយ។ នោះនឹងធ្វើឲ្យយើងបានស្គាល់ពីសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះអ្នក ហើយស្រឡាញ់ទំនាក់ទំនងដែលអ្នកមានជាមួយព្រះយេស៊ូវ។ អធិស្ឋានសម្រាប់កុមារណាដែលអាចនឹងត្រូវការជួបព្រះនៅថ្ងៃនេះ។

អំពើបាប

សេចក្ដីស្រឡាញ់

ការអត់ទោស

# ព្រះយេស៊ូវស្រឡាញ់ខ្ញុំ និងអត់ទោសឲ្យខ្ញុំ



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________

______________________________________________

______________________________________________